KO 3331
TSL BOX 4

ករណី - សួ . សំរិត

- អាយុ ៣៩ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

. អតីត. កម្មកររោងចក្រ កង់ឡាន តាខ្មៅ ។

- បច្ចុប្បន្ន កម្មករ ក.១

. សេពគប់ ដើរផឹកស៊ី និង ចេញចូល ចុះឡើង ជាមួយឈ្មោះ ឌី.ប៉ាន់

. សេរីភា ៧១ បច្ចុ. នៅ ក.១ " ក៏បានទទួលការអប់រំ

នយោបាយ ជាបណ្តើរៗ ពីឈ្មោះនេះ ។ ទីបំផុត ក៏ព្រម ចូល

សេរីភា តាមការអូសទាញ ។

១.៧៣ - បានចូល សេរីភា នៅរោងចក្រ កង់ឡាន តាខ្មៅ

អ្នកនាំចូល ឌី.ប៉ាន់

អ្នកទទួលស្គាល់ អ៊ុម.ស៊ីនឿន " សេរីភា បច្ចុ. មិនដឹង -

ប្រាក់ខែ ៧០ ដុល្លារ ។

ភារកិច្ច ឃោសនាប្រឆាំង បដិវត្ត ពង្រីកកម្លាំង សេរីភា និង
ដើរស៊ើករកបណ្តាញខ្មែរក្រហម - ស៊ើបសកម្មភាពទម
ទាហាន ដែលលក់អង្ករ ប្រេងឥន្ធនៈ ថ្នាំពេទ្យ និង
អាវុធ ទៅតំបន់ រំដោះ ។

សកម្មភាព . ក្រោយ ១៧.៤.៧៥ :

- បានភ្ជាប់ខ្សែ រយៈ ជាមួយ ពិន.ថុន ហើយធ្វើសកម្មភាពប្រឆាំងបដិវត្ត

ក្នុងក្រុម ប្រាក់.សារី " សេអ៊ីអា កម្មករ ក ១ . បច្ចុ. ចាប់ខ្លួន

- បានឃោសនា បំបែកកម្មករចាស់ ពីអង្គការបដិវត្ត ដូចជា ថា កុំជឿ-អង្គការបដិវត្ត ថ្ងៃក្រោយ វាគ្មានសំបូរសប្បាយ អីទេ វាមុខតែបានតែមួយផ្អែតហ្នឹង កុំជឿកម្មាភិបាល ថា កសាងសង្គមស្មើភាព មើលតែឥឡូវទៅដឹងហើយ កម្មាភិបាល រស់នៅធ្វើការងារស្រួល ឯកម្មករចាស់ រស់នៅ នឹង ធ្វើការងារ ដូចសត្វ ៗ
- **បានចលនា** កម្មករឱ្យឡើង តវ៉ា ទាមទារពេលសំរាក សិទ្ធិសេរីភាព-ដើរហើរ ៗ
- បានធ្វើឱ្យខូច គុណភាព កៅស៊ូ អស់ ៥០ គ.ក្រ ៗ
- បានធ្វើឱ្យខូច ម៉ាស៊ីន បិតកៅស៊ូទំផ្ទុ ក្នុងកង់ អស់ ១ ផង ៗ
- បានធ្វើឱ្យ ម៉ាស៊ីន រអាក់រអួលជាញឹកញាប់ ៗ